# ការចិញ្ចឹមទាជាលក្ខណៈគ្រួសារ

## សេចក្តីផ្តើម

ការចិញ្ចឹមទាជាផ្នែកមួយសំខាន់ដែលទាផ្តល់សាច់ និងស៊ុតជាម្ហូបអាហារសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង ហើយទាជាសត្វដែលចិញ្ចឹមឆាប់ទទួលបានផលចំណេញ សម្រាប់សេចក្តីត្រូវការរបស់យើងទាន់ពេល និងជួយបង្កើនប្រាក់ចំណូលទៀតផង។ ម្យ៉ាងទៀតទាជាសត្វដែលងាយចិញ្ចឹមហើយឆាប់ទទួលបានផល ហើយវាមានតួនាទីសំខាន់ណាស់ក្នុងការរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងលើកកម្ពស់សុវត្ថិភាពស្បៀងសម្រាប់ប្រជាកសិករទាំងមូល ។ មុនពេលចិញ្ចឹមទាយើងគួរតែ សិក្សាស្រាវជ្រាវឱ្យបានល្អិតល្អន់ជាមុនសិននូវបច្ចេកទេសចិញ្ចឹម ទោះបីការចិញ្ចឹមនោះមានទ្រង់ទ្រាយតូចតាច ដូចការចិញ្ចឹម ជាលក្ខណៈគ្រួសារ ឬចិញ្ចឹមបែបជាឧស្សាហកម្ម ធ្វើយ៉ាងនេះទើបការចិញ្ចឹមរបស់យើងនឹងទទួលបានផលល្អ ថែមទាំងមានការ សន្សំសំចៃ ចំណេញពេលវេលា និងចំណេញថវិការផង។

ទាជាសត្វងាយចិញ្ចឹម វាមិនទាមទាជម្រក ឧបករណ៍ប្រើប្រាស់សម្រាប់ចិញ្ចឹមច្រើនណាស់ណាទេ និងមានតម្លៃខ្ពស់នោះឡើយ អាចចិញ្ចឹមដោយការបំប៉នចំណី ឬលែងឱ្យវាស៊ីដោយខ្លួនឯងនៅតាមវាលស្រែ បឹង បួ ស្រះ ត្រពាំង។

❶ **<u>សារៈសំខាន់នៃការចិញ្ចឹមទា:</u>** ការចីញ្ចឹមទាមានសារៈសំខាន់ដូចជា:

- សម្រាប់យកសាច់ និង ពងជាអាហារ
- សម្រាប់បង្កើនប្រាក់ចំណូលក្នុងគ្រួសារ
- ងាយស្រួលចិញ្ចឹមព្រោះអាចចិញ្ចឹមលើដីផ្ទាល់ មិនពិបាកធ្វើទ្រុងហើយទ្រុងមិនត្រូវការសម្ភារៈទំនើប
- លាមកទាសម្រាប់ធ្វើជីសម្រាប់ដាក់ដំណាំកសិកម្ម
- រោមស្លាបទាសម្រាប់ធ្វើឧបករណ៍ផ្សេងៗ ដូចជាអំបោស ឬ ខ្នើយ ។ល។





❷ **អំពីពូជទា:** ប្រភេទទាដែលគេចិញ្ចឹមមានដូចជា ទាចិញ្ចឹមយកសាច់ ទាចិញ្ចឹមយកពង និងទាចិញ្ចឹមយកសាច់ផង និងយកពងផង។

- ទាយកសាច់ប៉េកាំង: ជាទាពូជយកសាច់ដែលគេនិយមចូលចិត្តមានដើមកំណើតនៅចិន ធំធាត់លឿន សាច់ច្រើន រោមពណ៌សចម្រុះ ពណ៌សចម្រុះ ពណ៌លឿងចាស់ ជើងពណ៌ស្វាទុំ មុខពណ៌លឿង។ ទម្ងន់មធ្យមឈ្មោល ៣,៥-៤ គ.ក្រ ញីមានទម្ងន់ ២,៥-៣ គ.ក្រ ហើយផ្តល់ពងប្រហែល ១៦០ គ្រាប់ ក្នុង ១ឆ្នាំ។
- ទាកាប៉ា: មានមាឌធំ គ្រប់ដណ្តប់ស្លាប់ពណ៌ខ្មៅ (ក្បាល ក) ធំភ្នែកមានរង្វង់ក្រហមព័ទ្ធជុំវិញ។ ជាទាសាច់ច្រើន ពងតិច ធំធាត់យឺតយ៉ាវ។ នាពេលបច្ចុប្បន្នគេនិយមចិញ្ចឹមសម្រាប់លក់ ទាធំឈ្មោលទម្ងន់ ៤-៤,៥ គ.ក្រ ញីទម្ងន់ ៣-៣,៥ គ.ក្រ។
- ទាសំពៅ: ជាទាដែលគេនិយមចិញ្ចឹមយកសាច់ផង និង យកពង។ ទាញីមានពណ៌សំបកអំពៅស្ទើរពេញខ្លួន។ ទាឈ្មោលមានក្បាលពណ៌ក្រហម ដងខ្លួនមានពណ៌ប្រផេះ ពោះពណ៌ស ចំពុះពណ៌ប្រផេះ ជើងពណ៌លឿងចាស់។ ជាពូជ ដែលគេនិយមចិញ្ចឹមណាល់ ព្រោះសាច់មានរស់ជាតិឆ្ងាញ់ និងស្រួលក្នុងការចិញ្ចឹម។
- ទាអង្កាម: ជាទាដែលគេនិយមចិញ្ចឹមយកសាច់ផង និង យកពង។ ពូជទានេះមានពណ៌ប្រផេះលឿងទុំ និងមានពណ៌ខ្មៅអ៊ុចៗ ក រាងខ្លី ដងខ្លួនរាងសំប៉ែត ជើងតូច ទម្ងន់មធ្យមពី ២-២,៥ គ.ក្រ។

**២-១- ការជ្រើសរើសកូនទា:** ការជ្រើសរើសកូនទាគឺត្រូវ:

- យកកូនទាណាដែលញាស់ចេញពីពងទាដែលមានមេ-បាល្អ
- កូនទារូបរាងល្អ សុខភាពល្អ រហ័សរហួន រោមស្ងួតរលោងត្រសុះល្អ មានជើងរឹងមាំ
- ភ្នែកឈ្លាសវៃ មិនល្មៀនពេក។ មិនត្រូវយកកូនទាណាស្លិក ឬ មានលក្ខណៈងុយដេកឡើយ។

**២-២- កំណត់ភេទកូនទា:** គេអាចកំណត់ភេទកូនទា នៅពេលវាកើតបានអាយុ១ថ្ងៃ ដោយប្រើវិធីពិនិត្យទៅលើក្លូអាក់ទា (គូទទា)ដោយចាប់កូនទាផ្ងារពោះឡើងលើ រួចយកម្រាមដៃញែកសងខាងក្លូអាក់កូនទា ហើយធ្វើការពិនិត្យមើលក្នុងក្លូអាក់របស់ទា។ បើកូនទាឈ្មោលគេឃើញមានលិង្គ (គ្រាប់ប៊ុនគ្រាប់ខ្សាច់) តែបើកូនទាញីគេពុំឃើញមានអ្វីឡើយ។

**២-៣- ការជ្រើសរើសមេទាសម្រាប់ទុកពូជ:** មេទាដែលជ្រើសរើសត្រូវមានអាយុយ៉ាងតិច ៨ ខែឬ បានពង ៣ ខែរួចមកហើយ (មេទាមិនត្រូវមានអាយុលើសពី ៣ ឆ្នាំឡើយ) ព្រោះងាយស្រួលតាមដានសាវតាររបស់វា។ ក្រៅពីនេះមេទាត្រូវមានលក្ខណៈគឺមេទាមិនធាត់ពេក និងមានសុខភាពល្អ។ ទាមានសុខភាពល្អសម្គាល់ដោយមានរោមរាបស្មើរលោង ភ្នែកល្មៀនបន្តិច ភ្លឺថ្លា រហ័សរហួនគ្រប់ពេលវេលា។ មេទាដែលមានពងច្រើនមានលក្ខណៈសម្គាល់គឺមានខ្នងទូលាយ ដងខ្លួនវែងប្រឡោះជើងទូលាយ (ឆ្អឹងទ្រូងធំ) ឆ្អឹងទ្រូងទន់ ស្បែកពោះស្តើងហើយទន់ គូទធំ។ មេទាដែលមានដើមទ្រូងខ្លី ដងខ្លួនចង្អៀតមិនត្រូវទុកពូជទេ។

**២-៤- ការជ្រើសរើសទាបា:** ទាបាទុកពូជគឺជាទាឈ្មោលដែលមានអាយុមិនតិចជាង ៦ ខែឡើយ យកល្អវាល់ទាបាត្រូវមានអាយុលើសមេទាឱ្យបានមួយខែ។ ទាបាត្រូវមានលក្ខណៈដូចតទៅគឺ សុខភាពល្អរហ័សរហួន ដងខ្លួនវែងសមរម្យ មានជើងមាំមួន។ ទាបាមួយអាចបង្កាត់នឹងមេទាចំនួន ៨ ទៅ ១០ ក្បាល។ ក្រោយពីបានបង្កាត់ចំនួន ៧ ទៅ ១០ ថ្ងៃក្រោយមកពងទាដែលបានពីមេទាអាចយកទៅភ្ញាស់បាន។

**២-៥- ការជ្រើសរើសពងទាសម្រាប់ភ្ញាស់:** ដើម្បីចិញ្ចឹមទាឱ្យទទួលលទ្ធផលល្អ យើងត្រូវជ្រើសរើសពងទាយកទៅភ្ញាស់។ ការធ្វើបែបនេះអាចជួយយើងទទួលបានកូនទាល្អមកចិញ្ចឹម។ ការជ្រើសរើសពងទាមានលក្ខណៈដូចតទៅ:

- យើងត្រូវជ្រើសរើសពងទាដែលស្អាត មិនត្រូវយកពងដែលចុងស្រួចស្រួចពេកឬមូលពេក។
- មិនត្រូវយកពងទាដែលមានសំបកស្តើង ឬ គ្រើម។
- ពងទាត្រូវមានទំហំធំ យកល្អទំងន់ពី ៧៥ ក្រាម ទៅ ៩៥ ក្រាម។
- ពងទាត្រូវរើសពីព្រលឹមព្រោះភាគច្រើន (៩៩%) មេទាពង ចាប់ពងពីម៉ោង ៣ យប់ដល់ម៉ោង ៧ ថ្ងៃ។
- ពងទាប្រលាក់ត្រូវជូតឱ្យស្អាត មិនត្រូវលាងទឹកឡើយ តែអាចលាង ឬ ជូតនឹងទឹកក្តៅឧណ្ហៗ។
- ពងទាអាចបង្កកំណើតនៅពេលដែលសីតុណ្ហភាពជុំវិញវាឡើងលើសពី ២៤ អង្សាសេ។ ដូចនេះត្រូវទុកពងទានៅកន្លែងត្រជាក់ជាង ២៤ អង្សាសេ យកល្អបំផុតគឺទុកនៅសីតុណ្ហភាព ១០ ទៅ ១៥ អង្សាសេ។
- កន្លែងទុកពងទាត្រូវក្រាលចំបើងឬអង្កាម ឆ្ងាយពីកន្លែងដែលមានក្លិនមិនល្អ ដូចជាក្លិនប្រេងម៉ាស៊ីន ខ្ទឹមជាដើម ហើយមិនត្រូវសើមឡើយ ។
- ត្រូវទុកពងទាផ្អែកខាងធំចុះក្រោម។ ពងទាសម្រាប់ភ្ញាស់មិនត្រូវទុកលើសពី ១០ថ្ងៃឡើយព្រោះពងដែលទុកយូរមិនសូវញាស់ល្អដូចពងដែលទាពងបានថ្មីៗឡើយ ។
- យកពងទាណាដែលមានបាត្រឹមត្រូវ។ ពងទាដែលមានបាតិចមិនសូវញាស់ឡើញ។

**២-៦- ការភ្ញាស់ពងទា:** ជាទូទៅពងទាអាចញាស់បានរយៈពេល ២៨ ថ្ងៃ ឯទាកាប៉ាមានរយៈពេល ៣៥ ថ្ងៃ ហើយសីតុណ្ហភាពសម្រាប់ញាស់គឺពី ៣៧,៥ អង្សាសេ ទៅ ៣៨ អង្សាសេ។ ការភ្ញាស់អាចធ្វើបានពីរបែបគឺ ការភ្ញាស់តាមលក្ខណៈធម្មជាតិ និងការភ្ញាស់ដោយសិប្បនិម្មិតគឺប្រើឧបករណ៍ភ្ញាស់ ឬ ទូភ្ញាស់។

**២-៧- ការភ្ញាស់តាមលក្ខណៈធម្មជាតិ:** ការភ្ញាស់តាមលក្ខណៈធម្មជាតិគឺជាការភ្ញាស់ដោយប្រើមេមាន់ឬមេទាកាប៉ាឱ្យក្រាបពងទាដែលយើងចង់ភ្ញាស់។ ជាធម្មតាទាពុំចេះក្រាបពងដោយខ្លួនឯងឡើយ។ វិធីនេះងាយស្រួលណាស់ដោយគ្រាន់តែប្តូរពងមាន់ចេញហើយដាក់ពងទាចូលជាការស្រេចទៅហើយ។ *មេមាន់អាចក្រាបពងបានចំនួនពងពី ១០ ទៅ ១២ ពង ឯចំណែកទាកាប៉ាវិញវាអាចក្រាបពងបានច្រើនរហូតដល់ ២០ ពង ឬ លើសពីនេះទៀតក៏បានដែរ។*

ដើម្បីឱ្យពងញាស់បានល្អត្រូវ: